**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ...០១...ណស.ណណ.ន..

# សេចក្តីណែនាំ

## ស្តីពី

## ការរៀបចំ និង ត្រួតពិនិត្យសំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់ សំរាប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង

កន្លងមកក្រសួង បានកត់សំគាល់ឃើញថា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត/ក្រុង មួយចំនួនបានធ្វើការងារពិនិត្យសំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់បានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសមុននឹងបញ្ជូនមកសាលាខេត្ត/ក្រុងឬ ក្រសួងដើម្បីពិនិត្យនិងសំរេច ក៏ប៉ុន្តែទន្ទឹមនឹងនេះក៏មាន មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង មួយចំនួនទៀត នៅមានចំណុចខ្វះខាតលើការរៀបចំ និងត្រួតពិនិត្យសំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់ ដោយពុំមានរបាយការណ៍បច្ចេកទេស និង យោបល់ជំនាញច្បាស់លាស់ទៅតាមការណែនាំរបស់ក្រសួង ។

ដើម្បីលុបបំបាត់បាតុភាពអសកម្មខាងលើ និងដើម្បីអោយការរៀបចំ និងត្រួតពិនិត្យសំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់កាន់តែមានសុក្រឹត្យភាព ប្រសិទ្ធភាព និង តម្លាភាព ក្រសួងធ្វើការណែនាំដូចខាងក្រោម :

I. សំណុំឯកសារ និងគំរោងប្លង់ សុំលិខិតអនុញ្ញាតសាងសង់ដែលចាំបាច់

សំណុំឯកសារសុំលិខិតអនុញ្ញាតសាងសង់ ដែលសាម៉ីសំណើត្រូវមានៈ

ក.សំណុំលិខិតសុំអនុញ្ញាតសាងសង់

១- សំណុំលិខិតសុំអនុញ្ញាតសាងសង់ ( ពាក្យសុំ កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន ..............)ដែលត្រូវ មានការចុះហត្ថលេខា ឬ ស្នាមមេដៃរបស់សាម៉ីសំណើ ។

២- ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ផតចំលង ដែលមានធ្វើ និត្យានុកូលកម្មនៅសាលាខេត្ត/ក្រុង ឬ កិច្ចសន្យាជួលដី ឬ ឯកសារបញ្ជាក់ពីការកាន់កាប់ដីសាងសង់ស្របច្បាប់ ។

- ករណីជួលដីរយៈពេលវែង( ១៥ ឆ្នាំ ឡើងទៅ) ត្រូវទៅចុះបន្ទុកនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត/ក្រុង ជាបុន ។

៣- អត្តសញ្ញាណសាម៉ីសំណើ : អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំណុំឯកសារសំគាល់និតិបុគ្គល ( ឯកសារ និងលក្ខន្តិកៈក្រុមហ៊ុន, លិខិតឆ្លងដែន, លិខិតប្រគល់សិទ្ធិ.....)

ខ. គំរោងប្លង់សុំលិខិតអនុញ្ញាតសាងសង់មាន :

( ចំនួនយ៉ាងតិច ១០ ច្បាប់ )

១- ប្លង់បង្ហាញទីតាំង មាត្រដ្ឋាន ១ ៖ ៥០០០ ឬ ១ ៖ ១០ ០០០

-សញ្ញាបង្ហាញទិស( ទិសខាងជើងទៅលើ)

២- ប្លង់សរុប( ប្លង់ទីតាំងអគារក្នុងដីឡូតិ៍ ) មាត្រដ្ឋាន ១ ៖ ២០០ ឬ ១ ៖ ៥០០ ដែលនៅលើប្លង់នេះបញ្ជាក់ពី :

- ការបោះទីតាំងនៃសំណង់ក្នុងដីឡូតិ៍ដែលជាកម្មវត្ថុនៃពាក្យសុំ
- ឈ្មោះ ឬ លេខផ្លូវធំ តូច និង ទំហំផ្លូវ
- ច្រកចេញចូលក្នុងដីឡូតិ៍
- ជួរតំរង់ផ្លូវ
- ជួរតំរង់នៃអគារ
- ទំហំដីនិងក្រឡាផ្ទៃដីឡូតិ៍ច្បាស់លាស់
- ចំងាយរវាងអគារនីមួយៗ ឬ ច្រើន
- ចំងាយពីព្រំប្រទល់ដីឡូតិ៍ ស្របច្បាប់ ទៅអគារស្នើសុំ
- ចំងាយទៅអគារជិតខាងដែលមានស្រាប់ជាប់ដីឡូតិ៍
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូតិ៍ ( ទីតាំង និង កំពស់)
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូតិ៍ជាប់គ្នា ផ្ទៃបាត និង កំពស់របស់វា
- ការរៀបចំផ្នែកផ្សេងៗនៃដីទំនេរ ( ដីដាំដំណាំ សួនច្បារ កន្លែងចតរថយន្ត )
- របង ( កំពស់ និងទីតាំង )
- បំពង់លូក្រៅអគារ ( រូបធាតុ វិជ្ជមាត្រ ចំណោត គិតកំពស់ រណ្តៅពិនិត្យ )
- កន្លែងតភ្ជាប់ទៅបណ្តាញលូសាធារណៈសំរាប់បញ្ចេញទឹកស្អុយ
- ទីតាំងអាងបង្គន់អនាម័យ អាងចំរោះ និង បណ្តាញប្រព័ន្ធបង្ហូរទឹក
- បណ្តាញទឹកស្អាត
- តារាងនិមិត្តសញ្ញា ឬ អក្សរកាត់ប្រើក្នុងសន្ទឹកប្លង់

៣- តារាងឈ្មោះអគារ ឈ្មោះសន្ទឹកប្លង់ ក្រឡាផ្ទៃសំណង់គ្រប់បន្ទប់ ជាន់ និងក្រឡាផ្ទៃសរុប

៤- ប្លង់អគារគ្រប់ជាន់ មាត្រដ្ឋាន ១ ៖ ១០០ នៅលើប្លង់នេះបញ្ជាក់ពី :

- មុខងារប្រើប្រាស់និងផ្ទៃក្រឡានៃអគារ
- សញ្ញានៃសង្ហារឹមស្របតាមមុខងារប្រើប្រាស់
- សញ្ញាសំគាល់រូបភាពពុះ និង រូបភាពរពារពីគ្រប់ទិស

៥- ប្លង់ដំបូល មាត្រដ្ឋាន ១ ៖ ១០០ នៅលើប្លង់នេះបង្ហាញពី :

- រចនាសម្ព័ន្ធ និង សំភារៈសំរាប់ដំបូល